សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍

Youth Coalition for Unity and Development

# គោលនយោបាយ

# ស្តីពី

# ការការពារកុមារ

ឆ្នាំ២០១៩

# មាតិកា


I.**អំពីសម្ព័ន្ធ**:............................................................................................០១

១.១ ទស្សនៈវិស័យ:...................................................................................... ០១

១.២ បេសកកម្ម:.........................................................................................០១

១.៣ គុណតម្លៃ:...........................................................................................០១

II.**សេចក្តីផ្តើមអំពីគោលនយោបាយការការពារកុមារ**:..........................................០១

២.១ គោលបំណងនៃគោលនយោបាយការពារកុមារ:.............................................០២

២.២ វិសាលភាពនៃគោលនយោបាយការពារកុមារ:...............................................០២

២.៣ និយមន័យនៃពាក្យកុមារ និងការរំលោភបំពានលើកុមារ:...................................០២

២.៤ ប្រភេទនៃការរំលោភបំពានកុមារ:.................................................................០៣

III.**គោលការណ៍ច្បាប់**:.......................................................................................០៤

៣.១ ការប្តេជ្ញាចិត្តរបស់យើងចំពោះការការពារកុមារ:.................................................០៤

៣.២ ក្រមសីលធម៌:.............................................................................................០៤

IV. **និតិវិធីសម្រាប់ការប្រតិបត្តិការណ៍គោលនយោបាយនេះ**:......................................០៦

៤.១ យន្តការដែលបង្កើតឡើងដើម្បីធានាលើការអនុវត្តនិគោលនយោបាយ:....................០៦

៤.២ ទំនួលខុសត្រូវចំពោះការអនុវត្ត:.......................................................................០៧

៤.៣ ការជ្រើសរើស ការសម្រាំង និងការណែនាំ/ តម្រង់ទិសបុគ្គលិកថ្មី:............................០៧

V. **ការរាយការណ៍ ការឆ្លើយតបចំពោះការរំលោភបំពានកុមារផ្ទៃក្នុង**:.......................០៧

VI . **ការឆ្លើយតបចំពោះលទ្ធផលនៃការស៊ើបអង្កេតផ្ទៃក្នុង**:.............................................០៨

VII. **ដំណើរការនៃការឆ្លើយតបកុមារដែលទទួលរងនូវការរំលោភ**.................................០៨

VIII. **ទោសប្បញ្ញត្តិ**:........................................................................................០៩

៨.១ គោលការណ៍ទូទៅ:.......................................................................................០៩

៨.២ កម្រិតនៃទោស:...........................................................................................១០

៨.៣ ការអនុវត្តន៍ដាក់ពិន័យ:..................................................................................១០

VIIII. **ការកែប្រែគោលនយោបាយ**:..........................................................................១១

## I. ប្រវត្តិរបស់សម្ព័ន្ធ

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៨ អង្គការ សមាគមយុវជនចំនួនប្រាំពីរដែលរួមមាន៖ វិទ្យាស្ថានសម្រាប់អភិវឌ្ឍន៍ជាតិ សមាគមយុវជនខ្មែរ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន អង្គការយុវជនខ្មែរ និងការអភិវឌ្ឍសង្គម មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព អង្គការយុវសន្តិភាព ក្រុមប្រឹក្សាយុវជនកម្ពុជា និងបុគ្គលមួយចំនួន បានរួមគ្នាបង្កើតសម្ព័ន្ធមួយឈ្មោះថា "**សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍** (សយឯអ) " ជាភាសាអង់គ្លេសថា "Youth Coalition for Unity and Development" (YCUD) ជាសម្ព័ន្ធយុវជននៅក្នុងប្រទេសកម្ពុជា ដែលបង្កើតឡើងដើម្បីធ្វើការរួមគ្នានិងចូលរួមចំណែកដោះស្រាយបញ្ហានានារបស់យុវជន ជាអាទិ៍មានការតស៊ូមតិឱ្យមានគោលនយោបាយយុវជនជាតិ លើកកម្ពស់ការគោរពសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទំនួលខុសត្រូវសង្គម ក៏ដូចជាបញ្ហាសុខភាព បរិស្ថាន និងការងារធ្វើជាដើម ។ល។

សម្ព័ន្ធ ស.យ.ឯ.អ គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនស្វែងរកកម្រៃ ជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍នយោបាយ ក្នុងនោះមានរួមទាំងមិនផ្តល់មធ្យោបាយជាសម្ភារ ហិរញ្ញវត្ថុធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយណាមួយឡើយ។

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍បានបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ហើយទទួលបានលិខិតឆ្លើយតបលេខ២៤៣៨ស.ជ.ណ ចុះថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០១៤ ។

### ក- ទស្សនវិស័យ:

ចង់ឃើញសង្គមកម្ពុជាមួយ ដែលសិទ្ធិអំណាចយុវជនគ្រប់ជំនាន់ត្រូវបានទទួលស្គាល់ក្នុងការចូលរួមអភិវឌ្ឍប្រទេសប្រកបដោយចេរភាព។

### ខ- បេសកកម្ម:

យុវជនធ្វើការរួមគ្នាដើម្បីពង្រឹង និងពង្រីកការចូលរួមរបស់យុវជននៅក្នុងកិច្ចការសង្គម តាមរយៈ ការកសាងសមត្ថភាព ការអប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ បរិស្ថាន សុខភាព ព្រមទាំងការតស៊ូមតិឱ្យមានការផ្លាស់ប្តូរស្ថានភាពយុវជនកម្ពុជា។

### គ- គុណតម្លៃ:

- សាមគ្គីភាព
- ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យ
- អហិង្សា
- តម្លាភាព និងគណនេយ្យភាព
- យេនឌ័រ។

## II. សេចក្ដីផ្ដើមអំពីគោលនយោបាយការការពារកុមារ

សម្ព័ន្ធយុវជនដើម្បីឯកភាពនិងអភិវឌ្ឍន៍ជឿជាក់ថាសុខមាលភាពកុមារគឺសំខាន់បំផុតហើយកុមារទាំងអស់មានសិទ្ធិការពារខ្លួនរួចផុតពីការធ្វើទុកបុកម្នេញឬការរំលោភបំពាននានា។ សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ប្ដេជ្ញាទប់ស្កាត់ពីការរំលោភបំពាន និងការពារកុមារទាំងឡាយនៅក្នុងប្រទេសកម្ពុជា ពីព្រោះថាកុមារជាច្រើននៅក្នុងប្រទេសកម្ពុជាកំពុងប្រឈមមុខពីការជួញដូរ កេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានទៅលើផ្លូវភេទ និងការរំលោភបំពានតាមគ្រប់រូបភាពផ្សេងៗទៀត...។ល។ការងាររបស់សម្ព័ន្ធគឺបន្តគោរពទៅតាមសទ្ធិសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ (UNCRC) រួមមានគោលការសំខាន់ៗចំនួន៤គឺ ៖

- ការមិនរើសអើង និងការការពារជាពិសេស
- ការផ្ដោតសំខាន់ទៅលើផលប្រយោជន៍របស់កុមារ រួមបញ្ចូលទាំងការចូលរួមរបស់កុមារ
- សិទ្ធិរស់នៅ និងការអភិវឌ្ឍ និងការរស់រានមានជីវិត
- ការគោរពឆន្ទះរបស់កុមារ ។

### ២.១ <u>គោលបំណងនៃគោលនយោបាយការការពារកុមារ</u>:

គោលនយោបាយការពារកុមារនេះមានគោលបំណងការពារកុមារពីគ្រប់ទម្រង់នៃការរំលោភបំពានផ្សេងៗ ហើយវាឆ្លើយតបទៅនឹងបេសកកម្មរបស់សម្ព័ន្ធដែលយើងធ្វើការដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងជាពិសេសជាងនេះគឺចង់ឲ្យកុមាររស់នៅប្រកបដោយសុខមាលភាព និងការអភិវឌ្ឍ ។ ក្នុងនេះផងដែរនឹងផ្ដោតសំខាន់ទៅលើចំនុចចំនួន៣ដូចខាងក្រោម៖

- **ការបង្ការ:** យើងនឹងធានាថា តាមរយៈការយល់ដឹង និងការអនុវត្តល្អរបស់បុគ្គលិក និងចូលរួមកាត់បន្ថយគ្រោះថ្នាក់មួយចំនួនចំពោះកុមារនៅក្នុងសហគមន៍ដែលយើងធ្វើការ
- **ការយល់ដឹង:** យើងនឹងធានាថា គ្រប់បុគ្គលិក និងអ្នកដទៃទៀត (រាប់បញ្ចូលទីប្រឹក្សាសមាជិកក្រុមប្រឹក្សាភិបាល អ្នកស្រាវជ្រាវ/ អ្នកទស្សនៈកិច្ច បុគ្គលិកស្ម័គ្រចិត្ត បណ្ដាញសហគមន៍ ដៃគូអ្នកផ្ដល់ជំនួយមូលនិធិ) យល់ដឹងអំពីបញ្ហានៃការរំលោភបំពានកុមារ ។
- **ការគោរព:** យើងនឹងធានាថាគ្រប់បុគ្គលិករបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ ទាំងអស់នឹងមានការគោរពទៅលើក្រមសីលធម៌ការការពារកុមារ ។

### ២.២ <u>វិសាលភាព</u> :

គោលនយោបាយការការពារកុមារនេះគឺអនុវត្តន៍សម្រាប់បុគ្គលិកទាំងអស់ សមាជិកក្រុមប្រឹក្សាភិបាល អ្នកស្ម័គ្រចិត្ត ម្ចាស់ជំនួយ បណ្ដាញយុវជន និងភ្ញៀវដែលទៅទស្សនៈកិច្ចគម្រោង និងសកម្មភាពផ្សេងៗរបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ។

២.៣ <u>និយមន័យកុមារ និងការរំលោភបំពានលើកុមារ :</u>

កុមារគឺសំដៅទៅលើបុគ្គលទាំងឡាយណា ដែលមានអាយុក្រោម១៨ឆ្នាំ[3] ។ ដោយយោងទៅតាម Child Wise Cambodia ការរំលោភបំពានលើកុមារ អាចមាននិយមន័យទូលំទូលាយថា គឺជាការធ្វើទុកបុកម្នេញទាំងឡាយណា ដែលប្រព្រឹត្តលើកុមារដល់រូបរាងកាយ សតិអារម្មណ៍ និង/ឬផ្លូវភេទ ដែលបន្ទុចបង្អាក់ ឬបំផ្លិចបំផ្លាញដល់ការអភិវឌ្ឍ និងសុខមាលភាពរបស់ពួកគេ។វាអាចរួមមានការរំលោភលើរូបរាងកាយ ការរំលោភបំពានខាងសតិអារម្មណ៍ ផ្លូវចិត្ត ការមើលរំលង ការរំលោភផ្លូវភេទ ពលករកុមារ និងការបង្ខិតបង្ខំកុមារឲ្យធ្វើការងារដោយ បំពានជាដើម ។

២.៤ <u>ប្រភេទនៃការរំលោភបំពានកុមារ</u>[4]

- **ការរំលោភបំពានផ្លូវកាយ:** ការបង្ករឲ្យមានស្នាមលើរាងកាយកុមារ ។ ការបង្ករបួសស្នាមនេះរួមមាន: ការដុត ការវាយតប់ ការកាប់ចាក់ ការក្តិចមួល ការចាប់ក្រវី ការទាត់ធាក់ ការឃុំឃាំងកុមារនៅក្នុងបន្ទប់ ការចងកុមារ ការដាល់តប់ ការបង្ករឲ្យមានការឈឺចុកចាប់ ការដាក់ថ្នាំបំពុល ការចាប់ជ្រមុជទឹក ឬការធ្វើអ្វីមួយដែលបង្កគ្រោះថ្នាក់ដល់កុមារ ។
- **ការរំលោភបំពានផ្លូវភេទ:** អាកប្បកិរិយាផ្លូវភេទដែលមិនស្របជាមួយកុមារ ។ ទង្វើរួមមាន: ការស្ទាបអង្អែលប្រដាប់ភេទរបស់កុមារ ការធ្វើឲ្យកុមារស្ទាបអង្អែលប្រដាប់ភេទរបស់មនុស្សចាស់ ការរួមរ័ក្ស ការចាប់រំលោភ ការរួមភេទតាមរន្ធគូទ ការកាត់ ឬធ្វើឲ្យដាច់ប្រដាប់ភេទកុមារ ការចូលចិត្តស្រាតបង្ហាញឲ្យគេមើល ការដាក់ឲ្យកុមារឃើញនៅស្ថានភាព ឬសម្ភារៈរួមភេទ និងការកេងប្រវ័ញ្ចដោយផ្ទាល់ ឬដោយប្រយោលដោយឲ្យកុមារចូលរួមជាមួយ (ឬការគំរាមកំហែងឲ្យកុមារចូលរួម) នៅក្នុងសកម្មភាពផ្លូវភេទមិនសមស្របផ្សេងៗ ។
- **ការរំលោភបំពានផ្លូវចិត្ត:** ជាការរំលោភបំពានខាងពាក្យសំដី ការរំលោភបំពានខាងគំនិតប្រាជ្ញា និងការរំលោភខាងចិត្តសាស្ត្រ ។ ការប្រព្រឹត្តិដោយឪពុកម្តាយ អាណាព្យាបាលដែលបានបណ្តាលឲ្យ ឬអាចបណ្តាលឲ្យមានបញ្ហា ស្មារតី ផ្លូវអារម្មណ៍ ផ្លូវចិត្តធ្ងន់ធ្ងរ។ វារួមមានទាំងការខកខាន/មិនបានធ្វើសកម្មភាពដើម្បីបង្ការអន្តរាយទាំងនេះ។ ការរំលោភបំពានផ្លូវចិត្តអាចរួមបញ្ចូលទាំងទំរង់ ឬរូបភាពខ្លះនៃការដាក់ទណ្ឌកម្មជ្រុលហួសហេតុពីសំណាក់ឪពុកម្តាយ\អាណាព្យាបាល ដូចជាការបង្ខាំងកុមារទុកនៅក្នុងបន្ទប់តូច ឬបន្ទប់ងងឹត ឬការចងកុមារភ្ជាប់ទៅនឹងកៅអីក្នុងរយៈពេលដ៏យូរមួយ ឬការគំរាមកំហែង ឬការសម្លុតកុមារ ការបំភ័យកុមារឲ្យខ្លាច ។ ទង្វើបែបនេះក៏រួមបញ្ចូលបន្ថែមទៀតផងដែរនូវសកម្មភាពធម្មតាមួយចំនួនដូចជា ៖ ការប្រមាថមើលងាយ ការធ្វើឲ្យអាម៉ាស់និងការបង្អាប់ចំពោះកុមារ ។ការបដិសេធកុមារម្តងហើយម្តងទៀត ការដាក់ងារឲ្យកុមារ និងការធ្វើការប្រៀបធៀបបែបអវិជ្ជមានទៅអ្នកផ្សេងទៀត ឬការរងកំហុសជំនួសគេ ឬការស៊ី

[3] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩

[4] ឯកសាររបស់សេវាសង្គមកិច្ចកម្ពុជា

បន្ទោស ការនិយាយ ប្រាប់ក្មេងថា វាឬនាងជាក្មេង មិនល្អ គ្មានតម្លៃ អាក្រក់ មានកំហុស ស្រែកគំហុកជាញឹកញាប់ ការគំរាមកំហែង ឬការរករឿងឆាឆៅ ការបន្លាចកុមារដោយចេតនា ការមិនយកចិត្តទុកដាក់ចំពោះកុមារ ជាការដាក់ទណ្ឌកម្ម ការមានទំនាក់ទំនងផ្លូវកាយតិចតួចពេក គ្មានការអោបរិត គ្មានការថើប ឬសញ្ញាផ្សេងៗទៀតនៃការស្រឡាញ់ អត់អោន ការដាក់ឲ្យកុមារឃើញអំពើហិង្សា ។

- **ការមិនអើពើ:** ការកើតឡើងម្តងហើយម្តងទៀតនៃការខកខាន/មិនបានត្រៀមសម្រាប់សេចក្តីត្រូវការជាមូលដ្ឋានទាំងផ្លូវកាយ និងផ្លូវចិត្តរបស់កុមារទោះបីជាមានអាហារ សំលៀកបំពាក់ អនាម័យខ្លួនប្រាណ ការថែទាំវេជ្ជសាស្ត្រសមរម្យ ឬការមើលថែរក្សាមានលក្ខណៈគ្រប់គ្រាន់ហើយក៏ដោយ ការរំលោភបំពានអាចរួមបញ្ចូលការបោះបង់ចោល និងរួមទាំងការខ្វះនូវសេចក្តីស្រឡាញ់ថ្នាក់ថ្នម ខ្វះការដាស់តឿនក្រើនរំលឹក ខ្វះការផ្តល់សុវត្ថិភាព និងខ្វះភាពកក់ក្តៅ ។

## III. គោលការណ៍ច្បាប់

៣.១ <u>ការប្តេជ្ញាចិត្តរបស់យើងចំពោះការការពារកុមារ</u> ៖

- សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ នឹងគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់កុមារដែលយើងធ្វើការជាមួយ ហើយប្រកាន់យកប្រយោជន៍កុមារជាធំ
- ការរំលោភបំពានលើកុមារ ជាករណីមិនអាចទទួលយកបាន
- សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ នឹងមានយន្តការការពារកុមារទាំងឡាយតាមរយៈគ្រប់គម្រោង និងកម្មវិធីនានារបស់យើង
- សម្ព័ន្ធយុវជនដើម្បីឯកភាពនិងអភិវឌ្ឍន៍នឹងចាត់វិធានការតឹងរឹងចំពោះបុគ្គលិករបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ណាដែលប្រព្រឹត្តការរំលោភបំពានកុមារ ។

ដើម្បីធានាបានចំពោះការប្តេជ្ញចិត្តខាងលើ សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ ប្តេជ្ញាចិត្តគាំទ្រ:

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ
- រដ្ឋធម្មនុញ្ញកម្ពុជាដែលនិយាយពីកុមារ និងច្បាប់នានាដែលចែងអំពីការការពារកុមារ.

៣.២ <u>ក្រមសីលធម៌នៃការការពារកុមារ៖</u>

ខ្ញុំ.............................................តួនាទី.............................ទីកន្លែងធ្វើការ...................... យល់ព្រមអនុវត្តតាមគោលនយោបាយការពារកុមារ ដែលគូសបញ្ជាក់ទាំងឡាយ ដើម្បីធានាដល់ការការពារសុវត្ថិភាពកុមារ និងទប់ស្កាត់ការរំលោភបំពានលើកុមារក្នុងកំឡុងពេល ដែលខ្ញុំធ្វើការសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៖

**ខ្ញុំនឹង៖**

- ស្នើសុំការអនុញ្ញាតយល់ព្រមពីកុមារ និងអាណាព្យាបាលជាមុន មុននឹងខ្ញុំអញ្ជើញកុមារទាំងនោះឲ្យចូលរួមកម្មវិធីនានារបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍

- សុំការយល់ព្រមពីកុមារ និង/ឬឪពុកឬម្តាយ និងអាណាព្យាបាលរបស់កុមារមុនពេលថតរូប ឬថតវីដេអូ ទៅលើកុមារ ។ជាផ្នែកមួយនៃការងារនេះ ខ្ញុំត្រូវពន្យល់អំពីការប្រើប្រាស់នូវរូបថត ឬវីដេអូទាំងនោះ ហើយខ្ញុំនឹងថតរូបកុមារដោយមានស្លៀកសំលៀកបំពាក់ ខោ ឬសំពត់
- ធានាថា រូបថត ខ្សែភាពយន្ត វីដេអូ និងឌីវីឌី បង្ហាញរូបភាពកុមារក្នុងលក្ខណៈមួយប្រកបដោយភាពថ្លៃថ្នូរ និង ការគោរព
- បំពេញការងារប្រកបដោយបរិយាកាសបើកចំហ ជៀសវាងអំពីស្ថានភាពបុគ្គល ឬឯកជនជាមួយកុមារទាំងឡាយ
- ផ្តល់ការគោរពចំពោះកុមារ ដោយមិនគិតពីពូជសាសន៍ សញ្ជាតិ ពណ៌សម្បុរ ភេទ ភាសា សាសនា ឆន្ទៈនយោបាយ ជនជាតិដើម ពិការភាព ឬស្ថានភាពដទៃឡើយ ។
- ធានាថា បើសិនអាចធ្វើទៅបាន ត្រូវអោយមានវត្តមានមនុស្សពេញវ័យម្នាក់ទៀតនៅពេលដែលខ្ញុំកំពុងធ្វើការងារជាមួយកុមារ ឬនៅជិតជាមួយកុមារ ។
- លើកទឹកចិត្តឲ្យមានប្រាស្រ័យទាក់ទងដោយចំហរវាងកុមារគ្រប់រូប យុវវ័យ ឪពុកម្តាយ និយោជិត និងអ្នកស្ម័គ្រចិត្ត ទាំងអស់ព្រមទាំងជំរុញឲ្យកុមារ និងយុវវ័យចូលរួមនៅក្នុងការសម្រេចចិត្តទាំងឡាយណាដែលប៉ះពាល់ទៅលើពួកគេ ។
- ទទួលខុសត្រូវដើម្បីធានាថា ខ្ញុំមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្ញុំ ហើយខ្ញុំនិងមិនធ្វើឲ្យធ្លាក់ខ្លួនទៅក្នុងស្ថានភាពមួយដែលអាចឲ្យគេធ្វើការចោទប្រកាន់ពីបទរំលោភបំពានទៅលើកុមារឡើយ ។
- ធ្វើការវាយតម្លៃខ្លួនឯង អំពីការប្រព្រឹត្តិ សកម្មភាព ភាសា និងទំនាក់ទំនងរបស់ខ្ញុំជាមួយកុមារ ។
- រាយការណ៍ភ្លាមៗអំពីបញ្ហាកង្វល់ឬការចោទប្រកាន់អំពីការរំលោភបំពានទៅលើកុមារដោយអនុលោមទៅតាមនីតិវិធីសមស្រប ។
- រាយការណ៍អំពីកង្វល់នានា ដែលទាក់ទងទៅ និងការរំលោភបំពានកុមារ និងហ៊ាននិយាយប្រសិនបើខ្ញុំសង្កេតឃើញសហការីរបស់ខ្ញុំណាម្នាក់មានការប្រព្រឹត្តិមិនសមរម្យពាក់ព័ន្ធទៅនឹងការគោរពកិច្ចការពារកុមារ ។

<u>ខ្ញុំនឹងមិនៈ</u>

- ប្រើប្រាស់ភាសាមិនសមរម្យ ដែលពាក់ព័ន្ធទៅនិងផ្លូវភេទ បង្កការវាយប្រហារ រើសអើងធ្វើឲ្យបាត់បង់ការគោរព ឬភាសា ដែលមានលក្ខណៈរំលោភបំពាននៅពេល ដែលនិយាយជាមួយកុមារ ឬយុវវ័យឡើយ ។
- ចូលរួមក្នុងការប្រព្រឹត្តិ ដែលមានគោលបំណងបង្កឲ្យមានការខ្មាស់អៀន លេងសើច មើលងាយ ឬធ្វើឲ្យអាប់ឱនដល់តម្លៃរបស់កុមារ ឬយុវវ័យ ឬបង្កឲ្យមាននូវការរំលោភបំពានផ្នែកស្មារតីទៅលើកុមារ ។

- វាយដំ ឬធ្វើបាបរាងកាយ ដាក់ទណ្ឌកម្មផ្នែករាងកាយ ឬកំណត់វិន័យប៉ះពាល់រាងកាយទៅលើកុមារណាម្នាក់។
- បង្កើតទំនាក់ទំនងជាមួយកុមារ ដែលអាចចាត់ទុកថាមានលក្ខណៈកេងប្រវ័ញ្ចឬ រំលោភបំពាន ។
- ទទួលយក ឬចូលរួមនៅក្នុងការប្រព្រឹត្តខុសច្បាប់ គ្មានសុវត្ថិភាព ឬរំលោភបំពានទៅលើកុមារ ។
- រើសអើង បង្ហាញនូវការប្រព្រឹត្តខុសគ្នា ឬលំអៀងទៅលើកុមារណារម្នាក់ និងព្រងើយកន្តើយចំពោះកុមារដទៃ ។
- ស្វែងរកដើម្បីធ្វើការទំនាក់ទំនង និងចំណាយពេលវេលាជាមួយកុមារណាម្នាក់ដែល មានទំនាក់ទំនងជាមួយ និងសកម្មភាពរបស់ការងារសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ក្រៅពេលវេលាបំពេញការងារផ្លូវការរបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ ។
- ជួលកុមារឲ្យធ្វើការងាររបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ ក្នុងលក្ខណៈមួយមិនសមរម្យដោយផ្អែកទៅលើអាយុ និងដំណាក់កាលអភិវឌ្ឍរបស់ពួកគេ ដែលបង្កភាពរាំងស្ទះដល់លទ្ធភាពរបស់ពួកគេក្នុងការទទួលបានការអប់រំ សកម្មភាពកម្សាន្ត ឬដែលធ្វើឲ្យពួកគេប្រឈមទៅនឹងគ្រោះថ្នាក់ជារបួសស្នាមគួរឲ្យកត់សំគាល់ ។
- ប្រើប្រាស់កុំព្យូទ័រ ទូរស័ព្ទដៃ ម៉ាស៊ីនថតវីដេអូ និងម៉ាស៊ីនថតរូប ក្នុងលក្ខណៈណាមួយមិនសមស្របដើម្បីគោលបំណងកេងប្រវ័ញ្ច ឬ បៀតបៀនទៅលើកុមារ ។
- រៀបអាពាហ៍ពិពាហ៍ជាមួយជនណាម្នាក់ ដែលមានអាយុក្រោម ១៨ឆ្នាំ ។
- រំលោភបំពានផ្នែករាងកាយ ផ្លូវភេទ ឬផ្លូវចិត្តលើសមាជិកណាម្នាក់នៃគ្រួសាររបស់ខ្ញុំ រួមមានដៃគូរ ភរិយា ស្វាមី កូន ឬ សាច់ញាតិផ្សេងទៀត ឬ បុគ្គលរស់នៅក្នុងផ្ទះរបស់ខ្ញុំ ។
- ជួលកុមារអោយបំរើការងារក្នុងផ្ទះ ឬ ធ្វើពលកម្មដទៃទៀត ដែលមិនសមស្របទៅនឹងអាយុ ឬ ដំណាក់កាលលូតលាស់របស់ពួកគេ ដែលបង្កភាពរាំងស្ទះដល់លទ្ធភាពរបស់ពួកគេក្នុងការទទួលបានការអប់រំ សកម្មភាពកម្សាន្ត ឬ ដែលធ្វើឲ្យគេប្រឈមទៅនឹងគ្រោះថ្នាក់ជារបួសស្នាមគួរ ។

## IV. នីតិវិធីសម្រាប់ការប្រតិបត្តិការណ៍គោលនយោបាយនេះ

### ៤.១ យន្តការដែលបង្កើតឡើងដើម្បីធានាលើការអនុវត្តន៍គោលនយោបាយ

ដើម្បីឲ្យការអនុវត្តគោលនយោបាយនេះអនុវត្តឲ្យមានប្រសិទ្ធិភាព យន្តការដែលបានបង្កើតឡើងដើម្បីធានាលើការអនុវត្តគោលនយោបាយនេះគឺ:

- ផ្សព្វផ្សាយព័ត៌មានពីគោលនយោបាយនេះឲ្យបានទូលាយដល់បុគ្គលិក

- បុគ្គលិកទាំងអស់ត្រូវចុះហត្ថលេខាលើក្រមសីលធម៌
- អនុវត្តនិន្ទវទោសបញ្ញាត្តិក្នុងគោលការណ៍នេះឲ្យមានតម្លាភាព
- បង្កើតគណៈកម្មាការផ្ទៃក្នុង/គណៈកម្មការស៊ើបអង្កេតការរំលោភបំពានកុមារ
- ប្រើប្រាស់អ្នកគ្រប់គ្រងផ្ទាល់ជាអ្នកតាមដាន និងរាយការណ៍
- ប្រើប្រាស់យន្តការរបស់អ្នកពាក់ពន្ធ័ខាងក្រៅ ដូចជាវិស័យតុលាការ...។

៤.២ <u>ទំនួលខុសត្រូវចំពោះការអនុវត្ត :</u>

ដើម្បីឲ្យគោលនយោបាយការពារកុមារនេះអនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់អ្នកសម្របសម្រួលផ្នែកប្រតិបត្តិការមនុស្សជាអ្នកទទួលខុសត្រូវ និងធានាថា គោលនយោបាយការពារកុមារនេះត្រូវបានធ្វើការណែនាំ និងផ្តល់ឯកសារចំពោះបុគ្គលិកចាស់ និងបុគ្គលិកថ្មីដែលកំពុងធ្វើការទាំងអស់ដោយបុគ្គលិកបានទទួលស្គាល់ និងចុះហត្ថលេខាលើក្រមសីលធម៌ដែលមានភ្ជាប់ជាមួយចំនួនពីរច្បាប់ ។ ឯកសារនេះគឺ០១ច្បាប់រក្សាទុកជាឯកសារបុគ្គលិកនៅការិយាល័យផ្នែកប្រតិបត្តិការ និង០១ច្បាប់ទៀតសម្រាប់បុគ្គលិករក្សាទុកខ្លួនឯង ហើយផ្នែកប្រតិបត្តិការក៏ត្រូវធានាផងដែរថាគ្រប់បុគ្គលិកទាំងអស់នឹងទទួលបាននូវព័ត៌មានអំពីការផ្លាស់ប្តូរនានាទាក់ទងទៅនឹងគោលនយោបាយនេះ ប្រសិនបើមាន ។

ម្យ៉ាងវិញទៀតបុគ្គលិក ដែលជាអ្នកគ្រប់គ្រងផ្ទាល់រួមមានៈ អ្នកសម្របសម្រួលកម្មវិធី អ្នកសម្របសម្រួលផ្នែកប្រតិបត្តិការ ព្រមទាំងអ្នកដែលគ្រប់គ្រងបណ្តាញផ្ទាល់នៅតាមសហគមន៍ គឺជាអ្នកទទួលខុសត្រូវដោយធានាថាបុគ្គលិកឬអ្នកដែលពាក់ព័ន្ធជាមួយការអនុវត្តគម្រោង (បណ្តាញ) បានយល់ និងអនុវត្តគោលនយោបាយនេះ ហើយត្រូវតែមានការរាយការណ៍ជាប្រចាំពីភាពមិនប្រក្រតីណាមួយ ដែលបានកើតឡើងនៅក្នុងកំឡុងពេលនៃការអនុវត្តន៍គោលនយោបាយនេះ ។

៤.៣ <u>ការជ្រើសរើស ការសំរាំង និងការណែនាំតម្រង់ទិសបុគ្គលិកថ្មី :</u>

ការជ្រើសរើសបុគ្គលិក អ្នកស្ម័គ្រចិត្តនេះ គឺមានសារៈសំខាន់ណាស់ក្នុងការជ្រើសរើសឲ្យធ្វើការនៅសម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ ទោះបីជាអ្នកនោះមានតួនាទីអ្វីក៏ដោយហេតុនេះសម្ព័ន្ធត្រូវតែធ្វើការយកចិត្តទុកដាក់ទៅលើការប្រកាសជ្រើសរើសបុគ្គលិក អ្នកស្ម័គ្រចិត្តដោយការជ្រើសសម្រាំង និងពិនិត្យមើលនូវប្រវត្តិរូបបុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងអស់ដើម្បីធានាថាពួកគេនឹងផ្តល់នូវសុវត្ថិភាព និងមានបុគ្គលិកលក្ខណៈសមស្របដើម្បី នឹងធ្វើការជាមួយកុមារ និងយុវវ័យនៅតាមសហគមន៍ ពិសេសបុគ្គលិកដែលកាន់គម្រោងកុមារ ។

ចំពោះបុគ្គលិកថ្មី គឺតម្រូវឲ្យអាននូវគោលនបាយការការពារកុមារចាប់ពីពេលចូលធ្វើការនៅថ្ងៃដំបូង និងត្រូវបានស្នើឲ្យធ្វើការចុះហត្ថលេខាលើក្រមសីលធម៌ស្តីពីការការពារកុមារនេះ។

បុគ្គលិក និងអ្នកស្ម័គ្រចិត្តនឹងត្រូវបានគាំទ្រនិងត្រួតពិនិត្យមើលតួនាទីរបស់ពួកគេដើម្បីលើកទឹកចិត្តពួកគេឲ្យក្លាយទៅជាអ្នកដើរតួនាទីគម្រូជាវិជ្ជមានសម្រាប់កុមារ និងយុវជនជំនាន់ក្រោយ។

ក្តីព្រួយបារម្ភណាមួយ ដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តរបស់ពួកគេ និងត្រូវបានលើកយកមកដោះស្រាយដោយពឹងផ្អែកទៅតាមនីតិវិធីនៃយន្តការការពារកុមារដែលមានចែង ។

## V. ការរាយការណ៍ ការឆ្លើយតបចំពោះការរំលោភបំពានកុមារផ្ទៃក្នុង

សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ធ្វើការជាមួយកុមារដោយប្រយោល ហេតុនេះបើសិនជាមានជនណាមួយបានដឹងអំពីការរំលោភបំពានកុមារទាក់ទងនឹងបុគ្គលិករបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ត្រូវទាក់ទងទៅអ្នកគ្រប់គ្រងផ្ទាល់ ឬអគ្គលេខាធិការ ។ ទន្ទឹមនឹងនេះបើសិនជាមានលទ្ធភាព គឺត្រូវរាយការណ៍ជាបន្ទាន់ជាលាយលក្ខ័ណ៍អក្សរក្នុងរយៈពេល២៤ម៉ោងដើម្បីឲ្យមានការស៊ើបអង្កេត និងអន្តរាគមទាន់ពេលវេលា។

បន្ទាប់ពីទទួលបានព័ត៌មានពីការរំលោភបំពានដោយបុគ្គលិករបស់សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ ចំពោះកុមារគឺប្រធានផ្នែកប្រតិបត្តិការត្រូវតែអញ្ជើញសមាជិកដែលពាក់ពន្ធ័ធ្វើការស៊ើបអង្កេតជាលក្ខណៈផ្ទៃក្នុង។ បុគ្គលិកដែលទទួលការចោទប្រកាន់ត្រូវការគោរពចំពោះភាពឯកជន ការសម្ងាត់ និងសិទ្ធិស្របច្បាប់ ។

បុគ្គលិកដែលត្រូវចោទប្រកាន់ពីបទរំលោភបំពានកុមារ ត្រូវផ្អាកការងារជាបណ្តោះអាសន្នដោយរក្សាប្រាក់បៀវត្សពេញលេញនៅកំឡុងពេលនៃការស៊ើបអង្កេតដោយមានរយៈពេលយ៉ាងយូរ១ខែ ។ បុគ្គលិកនោះត្រូវបានជូនដំណឹងអំពីការចោទប្រកាន់ ហើយមានឪកាសឆ្លើយតប ហើយគាត់ក៏ត្រូវបានជូនដំណឹងផងដែរថាសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ នឹងធ្វើការស៊ើបអង្កេតផ្ទៃក្នុងហើយលទ្ធផលនៃការស៊ើបអង្កេតនឹងត្រូវផ្ញើជូនក្រុមប្រឹក្សាភិបាល ។ ក្នុងកំឡុងពេលធ្វើការស៊ើបអង្កេតចំពោះបុគ្គលិកផ្សេងទៀតដែលបានដឹងព័ត៌មានត្រូវអញ្ជើញមកធ្វើជាសាក្សី ។

## VI. ការឆ្លើយតបចំពោះលទ្ធផលនៃការស៊ើបអង្កេតផ្ទៃក្នុង

ក្នុងករណីការចោទប្រកាន់រកឃើញថា បុគ្គលិកសម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ពិតជាបានរំលោភបំពានលើកុមារក្នុងចំណុចណាមួយដែលមានចែងក្នុងប្រភេទនៃការរំលោភបំពាន នោះសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ នឹងអនុវត្តន៍ទៅតាមទោសបញ្ញាតិ ដែលមានចែងនៅក្នុងគោលនយោបាយធនធានមនុស្ស ឬមានចែងនៅក្នុងគោលនយោបាយនេះ។ ប៉ុន្តែបើសិនជាការរំលោភបំពានមានលក្ខណៈធ្ងន់ធ្ងរ ដែលតម្រូវឲ្យជាប់ទោសព្រហ្មទណ្ឌតាមច្បាប់ជាតិនៅក្នុងប្រទេស នោះសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ នឹងរាយការណ៍ជាលាយលក្ខណ៍អក្សរជូនទៅអាជ្ញាធរ ហើយសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍នឹងសហការនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតខាងក្រៅនេះ។បើសិនជាជនជាប់ចោទជាជនបរទេសសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ នឹងផ្តល់ព័ត៌មានទៅស្ថាប័នដែលពាក់ពន្ធ័ ។

ក្នុងករណីបុគ្គលិកដែលបណ្តេញចេញ ឬជាប់ទោសព្រហ្មទណ្ឌមានតែសមាជិកក្រុមប្រឹក្សាភិបាលទេ ដែលអាចធ្វើការទាក់ទងជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មានបាន ។

ប៉ុន្តែបើសិនជាការរំលោភបំពាននោះមានលក្ខណៈបន្តិចបន្តួច នោះសម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ នឹងស្រាយទៅតាមលក្ខណៈសម្រុះសម្រួលជាមួយកុមារ អាណាព្យាបាលរបស់កុមារ និងធ្វើការព្រមានជាលាយលក្ខណ៍អក្សរចំពោះបុគ្គលិក ។

ចំពោះបុគ្គលិក ដែលបានប្រព្រឹត្តរំលោភបំពានលើកុមារបានប្រព្រឹត្តិនៅកន្លែងរបស់យើង ហើយបានដាក់ពាក្យទៅធ្វើការនៅកន្លែងផ្សេង.... ពេលដែលមានអ្នកណាមួយទាក់ទងមកកន្លែង ចាស់ដើម្បីសួរ (Reference) គឺសម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍នឹងផ្តល់ព័ត៌មានពីការពិតអំពីប្រវត្តិនៃការធ្វើការងារជាមួយសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ។

## VII. ដំណើរការនៃការឆ្លើយតបកុមារដែលទទួលរងនូវការរំលោភ

នៅពេល ដែលមានកុមារម្នាក់នៅក្នុងសហគមន៍របស់យើងកំពុងជួបប្រទះនឹងការរំលោភ ហើយពេលនោះគាត់បានមកជួបបុគ្គលិករបស់យើង ។ អ្វីដែលបុគ្គលិកសម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ គួរធ្វើនៅពេលដែលមានកុមារមករកយើងគឺ:

- ទទួលរាក់ទាក់កុមារយ៉ាងកក់ក្តៅ និងផ្តល់សុវត្ថិភាពចំពោះកុមារ
  - ប្រើប្រាស់ឯកសារពាក់ព័ន្ធក្នុងការសាកសួរ
  - លើកទឹកចិត្តឲ្យគាត់ហ៊ាននិយាយការពិត
  - បង្ហាញឲ្យគាត់ឃើញថា យើងយកចិត្តទុកដាក់ និងជឿជាក់នូវអ្វីដែលគាត់បានបង្ហាញ
  - កត់ត្រានូវព័ត៌មានដែលពិតប្រាកដ មិនបំផ្លើស ឬវិនិច្ឆ័យដោយខ្លួនឯង
  - រក្សានូវព័ត៌មានដែលទទួលបានពីកុមារដោយភាពមានវិជ្ជាជីវៈ និងក្រមសីលធម៌
- ផ្តល់ការណែនាំ និងដំបូន្មាន ព្រមទាំងផ្តល់ជាសេវាព្យាបាលក្នុងករណីចាំបាច់
- រក្សាព័ត៌មានកុមារជាសំងាត់ និងរាយការណ៍ទៅអ្នកដែលមានសមត្ថកិច្ច

ក្នុងស្ថាប័ន៖

- យោងទៅលើនិតិវិធីក្នុងគោលការនយោបាយការការពារកុមារ
- ការស៊ើបអង្កេតផ្ទៃក្នុង និងរាយការណ៍ទៅគណៈកម្មាធិការប្រតិបត្តិ
- ការសម្រេចរបស់គណៈកម្មាធិការ គឺទៅតាមអ្វីដែលជាលទ្ធផលដែលបានរកឃើញ
- រាយការណ៍ទៅសមត្ថកិច្ចក្នុងករណីមួយដែលមានកំហុសធ្ងន់ធ្ងរ
- ផ្តល់ព័ត៌មានជាក់លាក់ណាមួយដល់អាជ្ញាធរ ។

ក្រៅស្ថាប័ន៖

- ផ្តល់របាយការណ៍ដល់ស្ថាប័នមានសមត្ថកិច្ច
- ជួយផ្តល់ ឬណែនាំទៅស្ថាប័នដែលផ្តល់សេវាកម្មសម្រាប់ជនរងគ្រោះ
- ផ្តល់ការសហការដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ។

- ក្នុងករណីរឿងធ្ងន់ធ្ងរ ហួសពីសមត្ថភាពរបស់យើងត្រូវតែសួរគាត់ថា រឿងនេះហួសពីសមត្ថភាពនៃការដោះស្រាយ ហេតុនេះយើងត្រូវតែសួរនាំជនរងគ្រោះ ហើយបញ្ជូនគាត់ទៅកន្លែងផ្សេង ហើយបើសិនជាកុមារមិនយល់ព្រមគឺគេត្រូវគិតជាឧត្តមប្រយោជន៍ចំពោះកុមារ ហើយត្រូវមើលពីស្ថានភាពជាក់ស្តែង...បើអាជ្ញាធរជាបងប្អូនរបស់ជនរងគ្រោះ គឺទៅអ្នកដែលអាចដោះស្រាយបាន ។

## VIII. ទោសប្បញ្ញត្តិ

៨.១ <u>គោលការណ៍ទូទៅ:</u>

វិធានដាក់ពិន័យនឹងត្រូវបានប្រើប្រាស់ក្នុងគោលបំណងធានា ការពារការប្រតិបត្តិនៃគោលនយោបាយការការពារកុមារឲ្យមានប្រសិទ្ធភាព។ការដាក់ពិន័យគឺប្រើប្រាស់ដើម្បីណែនាំ កែរលំអ ឬព្រមានបុគ្គលិកទាំងឡាយណា ដែលមានកំហុសឲ្យបង្កើនការទទួលខុសត្រូវ ឬបណ្តេញចេញនូវបុគ្គលិកដែលប្រព្រឹត្តខុសដដែល ឬធ្ងន់ធ្ងរ ។

៨.២ <u>កម្រិតនៃកំហុស :</u>

### *កំរិតធ្ងន់ធ្ងរ*

- ការចាប់រំលោភផ្លូវភេទកុមារ
- បៀតបៀនកេរ្តិ៍ខ្មាស់
- ការវាយដំដោយរំពាត់
- ការសំឡុត ឬគំរាម
- ការជួញដូរកុមារ
- ការឃុំឃាំង
- ការបង្អត់អាហារ និងការដាក់ថ្នាំបំពុលកុមារ។

### *កំរិតមធ្យម*

- បរិហារកេរ្តិ៍កុមារ
- ការើសអើង
- ឲ្យកុមារមើលរូបអាសភាស
- ទុកចោលមិនអើពើរ
- បបួលកុមារដើរលេងតែពីរនាក់
- មិនឲ្យកុមារទៅរៀន
- មិនជួយអន្តរាគមន៍ពេល ដែលកុមារមានបញ្ហា។

### *កំរិតស្រាល*

- ជេរប្រមាថ

- ឃើញកុមារយំហើយដើរហួស
- សំឡុត
- ដាក់ងារឲ្យកុមារ
- ថតរូបកុមារដោយមិនមានសំលៀកបំពាក់
- ជួបកុមារតែពីរនាក់នៅកន្លែងស្ងាត់
- មិនបោកខោអាវឲ្យកុមារ
- និយាយពាក្យមិនពីរោះទៅកុមារ
- ស្តីឲ្យកុមារនៅចំពោះមុខគេ
- សំឡុក់ ពេបជ្រាញ ភូត កុហាក បំភ័យ ...។

៨.៣ <u>ការអនុវត្តន៍ដាក់ពិន័យ:</u>

**ក. ការព្រមានផ្ទាល់មាត់៖**

- ការព្រមានផ្ទាល់មាត់អាចធ្វើឡើងចំពោះកំហុសកំរិតស្រាល និងកំរិតមធ្យម ដោយអ្នកគ្រប់គ្រងផ្ទាល់ ។

**ខ. ការព្រមានជាលាយលក្ខណ៍អក្សរ៖**

- ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះបុគ្គលិក ដែលបានធ្វើខុសនៅកម្រិតមធ្យម ហើយអគ្គលេខាធិការត្រូវចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរត្រូវផ្តល់សំណៅចំលងដល់សាមីខ្លួននិងច្បាប់ដើមដាក់ក្នុងសំណុំឯសាររបស់បុគ្គលិករូបនោះ។
- ក្នុងករណីអគ្គលេខាធិការធ្វើខុស គឺប្រធានក្រុមប្រឹក្សាភិបាលជាអ្នកសម្រេចដាក់ទោស ឬចេញលិខិតព្រមាននានា ។

**គ. ការបណ្តេញចេញ**

- បុគ្គលិកដែលប្រព្រឹត្តកំហុសធ្ងន់ធ្ងរនឹងត្រូវបណ្តេញចេញ ហើយសម្ព័ន្ធយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ ត្រូវតែបញ្ជូនបុគ្គលិករូបនេះទៅអាជ្ញាធរដើម្បីដោះស្រាយទៅតាមច្បាប់ជាតិ
- ត្រូវអនុវត្តវិធានបណ្តេញចេញផងដែរ ចំពោះបុគ្គលិកដែលត្រូវទទួលបានការព្រមានជាលាយលក្ខណ៍អក្សរលើកទីបី ។
- លិខិតបណ្តេញចេញត្រូវចេញដោយអគ្គលេខាធិកា សម្ព័ន្ធយុវជនដើម្បីឯកភាព និង អភិវឌ្ឍន៍ បន្ទាប់ពីមានការសម្រេចដោយគណៈកម្មាធិការប្រតិបត្តិ ឬចេញដោយប្រធានសមាជិកក្រុមប្រឹក្សាភិបាលបន្ទាប់ពីការប្រជុំសម្រេចរបស់សមាជិកក្រុមប្រឹក្សាភិបាល ។

## ១៦. ការធ្វើវិសោធនកម្មគោលនយោបាយហិរញ្ញវត្ថុ

គោលនយោបាយការពារកុមារនេះនឹងត្រូវធ្វើការចម្លងជូនដល់បុគ្គលិកឲ្យបានគ្រប់គ្នា ។ អ្នកសម្របសម្រួលប្រតិបត្តិការមានតួនាទីសំខាន់ក្នុងការណែនាំឲ្យបុគ្គលិកទាំងអស់នៅក្នុងសម្ព័ន្ធយល់ពីការអនុវត្តតាមគោលនយោបាយនេះ។

គោលនយោបាយនេះ នឹងធ្វើការកែសម្រួលនៅពេលមានការស្នើសុំជាចាំបាច់របស់សម្ព័ន្ធដោយមានការស្នើសុំ៥០បូកមួយចំនួនបុគ្គលិកសរុប ឬពីសមាជិកក្រុមប្រឹក្សាភិបាលយ៉ាងហោចណាស់២នាក់ ឬពិនិត្យឡើងវិញជារៀងរាល់៥ឆ្នាំម្តងដោយមានការចូលរួមពីបុគ្គលិក និងសមាជិកក្រុមប្រឹក្សាភិបាល ឬអ្នកពាក់ព័ន្ធនានាផងដែរ ។ រាល់ការកែសម្រួលនឹងត្រូវមានការអនុម័តពីក្រុមប្រឹក្សាភិបាល។

គោលនយោបាយនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី........ខែ...............ឆ្នាំ ២០១៥

**អគ្គលេខាធិការស្តីទី**

រាជធានីភ្នំពេញ.ថ្ងៃទី ...........ខែ .............ឆ្នាំ២០១៥

**ប្រធានក្រុមប្រឹក្សាភិបាល**

កន្លែងទទួល

- សមាជិកក្រុមប្រឹក្សាភិបាល (ដើម្បីជូនជ្រាប)
- បុគ្គលិក ( ដើម្បីអនុវត្ត )
- ឯកសារកាលប្បវត្តិ

# ការការពារកុមារ និង
# អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារច្រើនត្រូវបានគេស្គាល់ថាUNCRC ឬ CRC ។ វាជាឯកសារបញ្ជាក់ពីសិទ្ធិផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ កុមារ។

UNCRCបានត្រូវអភិវឌ្ឍន៍ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ។ វាបានត្រូវគាំទ្រដោយ១៩៤ ប្រទេសជុំវិញពិភពលោក ។ វាផ្តល់ការអបអរចំពោះវ័យកុមារ និងដាក់បញ្ចូលសិទ្ធិនានា ដែលកុមារនៅលើផែនដីត្រូវទទួលបានឲ្យទៅជាច្បាប់អន្តរជាតិ ។

អនុសញ្ញានេះមាន៥៤មាត្រា (ឬសេចក្តីថ្លែង) ដែលរៀបរាប់ពីសិទ្ធិនានាដែលកុមារគួររីករាយជាមួយ ។មាត្រាទាំងនោះសំខាន់បំផុតនៅពេលដែលពិចារណាពីចំណុចការពារកុមារដែលបានត្រូវសង្ខេបដូចខាងក្រោមៈ

មាត្រា១

" កុមារមានន័យថាជាមនុស្សទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ ។

មាត្រា២

កុមារត្រូវទទួលបានការប្រព្រឹត្ត " ដោយមិនមានការរើសអើងទោះក្នុងទម្រង់ណាមួយក៏ដោយ ដោយមិនគិតពីពូជសាសន៍ ពណ៌ សម្បុរ ភេទ ភាសា សាសនា និន្នាការនយោបាយ ឬគំនិតផ្សេងៗគ្នា ជាតិសាសន៍ ជនជាតិដើម ទ្រព្យសម្បត្តិ ពិការភាព ស្ថានភាពកំណើត ឬឋានៈផ្សេងឡើយ ។ "

មាត្រា៣

" គ្រប់សកម្មភាពទាំងអស់ជាមួយកុមារ ... ឧត្តមប្រយោជន៍របស់កុមារត្រូវតែទៅយកមកគិតជាចម្បង ។ "

មាត្រា៦

"..រាល់កុមារទាំងអស់មានសិទ្ធិជាប់មកជាមួយសម្រាប់រស់រានមានជីវិត..និងការអភិវឌ្ឍ។ "

មាត្រា៩

"...កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេដោយប្រឆាំងនឹងឆន្ទៈរបស់ពួកគេនោះទេ ។ "

មាត្រា១២

"...កុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួនមានសិទ្ធិបញ្ចេញទស្សនៈទាំងនោះ។ "

មាត្រា១៣

" កុមារត្រូវមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ "

មាត្រា១៩

" កុមារត្រូវតែទទួលការការពារពី... រាល់ទម្រង់នៃការប្រើអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្ត របួស ឬការរំលោភបំពាន ការមិនអើពើ ឬការប្រព្រឹត្តិបែបមិនអើពើ ការធ្វើបាប ឬការកេងប្រវ័ញ្ចរួមបញ្ចូលទាំងការរំលោភបំពានផ្លូវភេទ ក្នុងខណៈស្ថិតក្នុងការថែរក្សាពីឪពុកម្តាយ ឬពីបុគ្គលណាផ្សេងទៀតដែលថែរក្សាកុមារ។ "

មាត្រា២៥

កុមារដែលត្រូវយកមកដាក់ក្នុងមណ្ឌលថែទាំមានសិទ្ធិ " ...យូរៗម្តងពិនិត្យមើលឡើង វិញពីការប្រព្រឹត្តិនានាផ្តល់ចំពោះកុមារ និងកាលៈទេសៈផ្សេងទៀតទាក់ទងនឹងការស្នាក់នៅរបស់ពួកគេ ។ "

មាត្រ៣២

កុមារត្រូវតែ " ...ទទួលបានការការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងការធ្វើការងារគ្រោះថ្នាក់នានា...គ្រោះថ្នាក់ចំពោះសុខភាពកុមារ ឬការអភិវឌ្ឍន៍ផ្លូវកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ និងផ្នែកសង្គមរបស់កុមារ។"

មាត្រា៣៣

រដ្ឋត្រូវតែ "...ការពារកុមារពីការប្រើគ្រឿងញៀនខុសច្បាប់។ "

មាត្រា៣៤

រដ្ឋត្រូវតែ"...ការពារកុមារពីរាល់ទម្រង់ទាំងអស់នៃការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានផ្លូវភេទ ។ "

មាត្រា៣៦

ភាគីរដ្ឋត្រូវការពារកុមារពីរាល់ការកេងប្រវ័ញ្ចផ្សេងៗទៀត ដែលធ្វើឲ្យមានមហន្តរាយដល់ផ្នែកណាមួយនៃសុខមាលភាពរបស់កុមារ។

មាត្រា៣៧

" មិនមានកុមារណាម្នាក់តម្រូវឲ្យទទួលទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មបែបឃោឃៅអមនុស្សធម៌ ឬបែបបន្ថោកបន្ទាប់ឡើយ។ "

មាត្រា៣៩

រដ្ឋត្រូវ " ...មានវិធានការសមស្របនានាដើម្បីលើកកម្ពស់ការធូរស្បើយផ្លូវកាយ និង ផ្លូវចិត្ត និងការធ្វើសមាហរណកម្មចូលក្នុងសង្គនៃជនរងគ្រោះកុមារពីទម្រង់ទាំងឡាយនៃការមិនអើពើពីការកេងប្រវ័ញ្ច ឬការរំលោភបំពាន ។ "

# សូចនាករ(កត្តាចង្អុលបង្ហាញ)តាមរយៈកុមារដែលគេមិនអើពើ

## ១. សូចនាករតាមរយៈកុមារៈ

<u>សូចនាករតាមរយៈរាងកាយៈ</u>

- ជំងឺដែលមិនបានព្យាបាល ឬជំងឺដែលកើតឡើងញឹកញប់ ឬរបួសផ្លូវកាយ។
- មិនត្រូវបានគេមើលថែទាំជាញឹកញាប់ ឬទុកចោលឲ្យនៅម្នាក់ឯង ឬអនុញ្ញាតឲ្យកុមារលេងនៅក្នុងស្ថានភាព និងបរិយាកាសដែលមិនមានសុវត្ថិភាព។
- គ្មានអនាម័យល្អគ្រប់ពេល(មិនសំអាតខ្លួន សក់កណ្តាញ់មិនកក់សាប៊ូ ជះក្លិនខ្លួនមិនល្អ)។
- ឃ្លានអាហារ ហត់នឿយ អស់កំលាំង និង ខ្វះអាហាររូបត្ថម្ភ។
- ជាញឹកញប់តែងស្លៀកសំលៀកបំពាក់ដែលមិនសក្តិសមទៅនឹងស្ថានភាពអាកាសធាតុ។
- ឈប់លូតលាស់ ហើយស្រកទម្ងន់យ៉ាងច្រើនគួរឲ្យកត់សំគាល់។
- ស្លេកស្លាំង ស្គមស្គាំង មាន "ផ្តាល់ខ្ញង"។
- ស្បែកមើលទៅស្ងួតខ្លាំងដោយសារការខ្សោះជាតិទឹក។
- មានអាការៈក្អួតចង្អោរ និងរាគរូសរយៈពេលយូរ។
- មិនបានឈានទៅដល់ដំណាក់កាលអភិវឌ្ឍន៍ដែលស្ថិតក្នុងកម្រិតអាយុរបស់ពួកគេ។
- ប្រើគ្រឿងញៀន និងគ្រឿងស្រវឹង។

<u>សូចនាករតាមរយៈអាកប្បកិរិយាៈ</u>

- មើលទៅហាក់ដូចជាគ្មានកំលាំងកំហែង មិនចង់ទាមទារអ្វីទាំងអស់(ឧ. យំតិចៗ)។
- មិនចាប់អារម្មណ៍ចំពោះបរិស្ថាន ឬអ្វីៗដែលនៅជុំវិញខ្លួន ។
- សម្តែងសកម្មភាពតិចតួច ឬគ្មានចលនាអ្វីសោះ (ឧ. គេងស្ងៀម)។
- មិនមានការឆ្លើយតបទៅនឹងការរំញោចពីមនុស្សប្លែកមុខ។
- អាចមានទំនោរទៅរកការលួចរបស់គេ។
- អាចរៀនខ្សោយ។
- អាចខ្លាចមិនចង់ទៅផ្ទះ។
- មានលក្ខណៈស្ទាក់ស្ទើរនៅពេលមានមនុស្សដទៃមកក្បែរផ្ទះរបស់ខ្លួន។
- បង្ហាញពីការយល់ដឹងអំពីការងារ និងការទទួលខុសត្រូវរបស់មនុស្សដែលមានអាយុច្រើនជាងខ្លួន។

- មករៀនយឺតយ៉ាវ ឬអវត្តមានជាញឹកញាប់។
- ជាញឹកញយ តែងមករៀនរូសរាន់ ហើយចេញពីសាលាយឺតយ៉ាវ។
- និយាយថាគ្មាននរណា ថៃពួកគេទេ។

**២. សូចនាករតាមរយៈអ្នកថៃរក្សា:**

- បោះបង់កុមារចោល។
- ជាញឹកញាប់ ត្រូវបានគេរកឃើញ រឺ តែងបាត់ខ្លួនពីការងារ។
- ការរស់នៅផ្ទះដែលរញ៉េរញ៉ៃគ្មានការរៀបចំ ដែលមិនសប្បាយចិត្ត រឺច្របូកច្របល់។
- នៅឯកកោ ពីអ្នកជិតខាង នឹងមិត្តភក្តិ។
- ទុកអោយកុមារឲ្យរស់នៅក្នុងជីវិតនៅផ្ទះ ដែលមិនមែនសុខភាពល្អឬគ្មានសុវត្ថិភាព ព្រមទាំងការអនុវត្តន៍ផ្សេងៗទៀត។
- បង្ហាញនូវឥរិយាបទដែលខ្វះឆន្ទៈចំពោះជីវិតទូទៅ។
- មានការរពឹងទុកដែលមិនស្រមស្រប/មិនសមហេតុផលចំពោះកុមារ ឧ. រំពឹងថាកុមារដែលមានអាយុ៦ឆ្នាំ ត្រូវចេះដាំស្ល។
- ទុកកុមារឲ្យនៅតែឯងរយៈពេលយូរ។
- សេពគ្រឿងញៀន និងគ្រឿងស្រវឹង។
- មានបញ្ហាផ្លូវចិត្ត។
- មិនខ្វល់អំពីកុមារ។

# សូចនាករ(កត្តាចង្អុលបង្ហាញ) តាមរយៈការរំលោភបំពានផ្លូវកាយ

**១. សូចនាករតាមរយៈកុមារៈ**

សូចនាករតាមរយៈរាងកាយ:

- ការបាក់ឆ្អឹងឆ្អែង និងរងរបួសម្តងទៀត។ ការបាក់ឆ្អឹងកើតលើកុមារអាយុក្រោម២ឆ្នាំ គឺជាបញ្ហាធ្ងន់ធ្ងរ។
- របួសផ្នែកខាងក្នុង។ ជួនកាលរបួសអស់ទាំងនេះត្រូវបានបង្ហាញឲ្យដឹងតាមរយៈការឈឺចាប់គ្រុន។ ជាធម្មតាអាចសម្គាល់បានតាមរយៈអន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រតែប៉ុណ្ណោះ។
- ការកើតឡើងព្រមគ្នានូវរបួសថ្មី និងរបួសចាស់។
- ការពុល។
- ស្នាមនៅលើកដៃ កជើង និងចង្កេះបង្ហាញថាកុមារត្រូវបានគេចង។
- ស្នាមរបួស (ស្នាមជាំ ហើម ស្នាមមុត រលាក ស្នាមខាំ បាក់ឆ្អឹង។ល។) ដែលមិនស្របគ្នាទៅនឹងការពន្យល់(ឧ. ស្នាមជាំដ៏ធំមួយកន្លែង)។
- ស្នាមជាំ ជាពិសេសកើតចំពោះទារក និងកុមារតូចៗ។
- ស្នាមរបួសដែលមានជារូបរាងរីទ្រង់ទ្រាយ ដែលមើលទៅដូចជារបស់អ្វីមួយដែលគេប្រើដើម្បីបង្កើតជាស្នាមរបួស (ឧ. ក្បាលខ្សែក្រវ៉ាត់ បាតដៃ ឆ្នាំងអ៊ុត ធ្មេញ រលាកភ្លើងបារី) ។
- របួសលើផ្ទៃមុខ ជាពិសេសកុមារ និងទារក និងកុមារដែលមិនទាន់គ្រប់អាយុចូលសាលា (ឧ. ស្នាមមុត ហើម ឈឺចាប់។ល។)
- របួសដែលមិនស្របគ្នាទៅនឹងអាយុ និងការអភិវឌ្ឍន៍របស់កុមារ។
- ស្នាមរលើងសក់នៅលើក្បាលរបស់កុមារដែលកន្លែងនោះអាចត្រូវបានគេបោចសក់។

សូចនាករតាមរយៈអាកប្បកិរិយា:

- កុមារប្រាប់នរណាម្នាក់ថាការរំលោភបំពានបានកើតឡើង។
- មិនទុកចិត្តមនុស្សពេញវ័យ ឬស្ទាក់ស្ទើរមិនចង់ទៅផ្ទះ។
- ឱ្យតម្លៃខ្លួនឯងទាប។
- អាកប្បកិរិយាដែលមានលក្ខណៈខ្លាំងជ្រុល អាចមានលក្ខណៈកាចខ្លាំង ឬគេចចេញពីគេឯងខ្លាំង។
- ខ្លាចឪពុកម្តាយ ឬខ្លាចមិនហានទៅផ្ទះ។
- ប៉ុនប៉ងរត់គេចខ្លួន និងខ្លាចមិនហានទៅផ្ទះ។
- គ្មានការប៉ុនប៉ងស្វែងរកការលួងលោមនៅពេលមានការឈឺចាប់។
- ចាត់ទុកថាខ្លួនឯងជាមនុស្សអាក្រក់ ហើយសមនឹងទទួលពិន័យ។
- មិនអាចនឹងនឹកឃើញឡើងវិញថាតើរបួសនោះកើតឡើងដូចម្តេច ឬផ្តល់នូវការបកស្រាយដែលមិនស៊ីគ្នា។

- ជាញឹកញយ តែងអវត្តមានពីសាលា/មណ្ឌល។
- អាចនឹងញោចខ្លួននៅពេលមានគេប៉ះពាល់ដោយមិនបានដឹងខ្លួនជាមុន។
- បង្ហាញអាកប្បកិរិយាយល់ស្របរហូត ហើយអន្ទះសារចង់ផ្គាប់ចិត្តអ្នកដទៃ (ដើម្បីកុំឱ្យមានគេធ្វើបាបខ្លួនទៀត
- គេងមិនស្កវលក់ ខ្លាចទីងងឹត យល់សប្តិអាក្រក់ញឹកញាប់។
- ក្រៀមក្រំ យំញឹកញាប់។
- ធ្លាក់ទឹកចិត្ត។
- ការចងចាំ និងការផ្ចង់អារម្មណ៍ខ្សោយ។
- ប្រុងប្រយត្ន័ ហើយ "ត្រៀមខ្លួន" ជានិច្ចហាក់ដូចជារងចាំរឿងអាក្រក់អ្វីមួយនឹងកើតឡើងអញ្ចឹង។
- មានការភ័យខ្លាចនៅពេលមានកុមារដទៃយំ ឬស្រែក។
- បង្ហាញនូវអាកប្បកិរិយាដែលត្រលប់ទៅរកភាពជាកុមារដែលមានអាយុតិចជាងអាយុពិតរបស់ខ្លួនដូចជាដេកនោមដាក់ខោឬលេងដី។

ចំពោះកុមារដែលមានអាយុច្រើនជាងកុមារដែលរៀបរាប់ខាងលើ:

- រត់គេចចេញ។
- មានអាកប្បកិរិយាខុសច្បាប់
- សេពគ្រឿងញៀន។
- ប្រើអាកប្បកិរិយាបែបផ្តើន (ដើម្បីឱ្យគេខឹង)
- ប៉ុនប៉ងសម្លាប់ខ្លួន។

**២. សូចនាករតាមរយៈអ្នកថែរក្សា:**

- ចោទប្រកាន់កុមារថាកុមារនិយាយកុហក់អំពីការរំលោភនោះ។
- ផ្តល់ការបកស្រាយទៅលើរបួស ដែលមានលក្ខណៈមិនគួរឱ្យជឿ មិនពេញលេញ ឬមិនសមហេតុផល។ ឧទាហរណ៍ឪពុកម្តាយអាចនឹងនិយាយថា "ក្មេងហ្នឹងងាយនឹងមានស្នាមជាំណាស់" "បង/ប្អូនប្រុសរបស់នាងវាយដំនាងរាល់ពេល ហើយធ្វើឱ្យមានស្នាមជាំ" "ក្មេងហ្នឹងមានចលនារាងកាយមិនសមស្របទេ ហើយងាយនឹងរងគ្រោះថ្នាក់ណាស់"។
- ផ្លាស់ប្តូរការបកស្រាយរបស់ពួកគេអំពីរបួសផ្សេងៗពីគ្នាទៅតាមពេលវេលា។
- ហាក់ដូចជាមិនមានការព្រួយបារម្ភអំពីស្ថានភាពរបស់កុមារ។
- ពន្យាពេលមិនព្រមស្វែងរកជំនួយផ្នែកវេជ្ជសាស្ត្រ។
- ប៉ុនប៉ងលាក់លៀមអំពីរបួសរបស់កុមារ។
- យកកុមារទៅជួបវេជ្ជបណ្ឌិត និងមន្ទីរពេទ្យផ្សេងៗជាច្រើន។
- ដាក់ពិន័យលើកុមារដោយមិនមានការចាំបាច់ ឬដោយឫកពារឃោឃៅ។
- បន្តរៀបរាប់អំពីកុមារដោយប្រើឫកពារបន្ទាបបន្ថោក
- បង្ហាញពីការឱ្យតម្លៃខ្លួនឯង និងការគ្រប់គ្រងលើខ្លួនឯងក្នុងកម្រិតទាប។

# សូចនាករតាមរយៈការរំលោភបំពានផ្លូវភេទ

## ១.សូចនាករតាមរយៈកុមារ:

សូចនាករតាមរយៈផ្លូវកាយ:

- មានចេញឈាម ឬធ្លាក់ឈាមតាមទ្វាមាស ឬរន្ធគូទ ។
- មានជម្ងឺកាមរោគ។
- ឈឺចាប់ ឬមាស់នៅត្រង់ប្រដាប់ភេទ ។
- មានផ្ទៃពោះ ។
- អស់កម្លាំងល្ហិតល្ហៃដោយគេងមិនលក់ ។
- ផ្លាស់ប្តូរទម្ងន់លឿន ។
- ដាច់ស្បែក ឬឈឺចាប់នៅលើដៃជើង បង្ករឡើងដោយកុមារខ្លួនឯង ។
- មានជម្ងឺផ្នែករាងកាយកើតឡើងច្រើនដង ។
- មានការលំបាកក្នុងការដើរ ឬអង្គុយ ។
- សម្លៀកបំពាក់ក្នុងមានលក្ខណៈដាច់រហែក ប្រឡាក់ដី ឬប្រឡាក់ឈាម ។
- មានរបួសត្រង់មាត់ ត្រង់ប្រដាប់ភេទ ឬត្រង់រន្ធគូទ (ឧ. ជាំ ហើម ឈឺ...) ។
- ជម្ងឺផ្លូវកាយដែលបង្ករឡើងដោយបញ្ហាផ្លូវចិត្ត ដូចជាឈឺពោះ ឈឺក្បាល ។

សូចនាករតាមរយៈអាកប្បកិរិយា:

ចំពោះកុមារដែលមានអាយុតិច

- ក្រៀមក្រំ យំញឹកញាប់ មានការថប់អារម្មណ៍ជ្រុល ។
- មានការផ្ទង់អារម្មណ៍រយៈពេលខ្លី ។
- សិកបញ្ចូលវត្ថុផ្សេងៗចូលទៅក្នុងទ្វាមាស ឬរន្ធគូទ ។
- ផ្លាស់ប្តូរ ឬបាត់បង់ចំណង់អាហារ ។
- គេងមិនលក់ យល់សប្តិអាក្រក់ ។
- ពឹងផ្អែកលើគេទាំងស្រុង ។
- ខ្លាចផ្ទះឬកន្លែងជាក់លាក់ណាមួយ ខ្វះជំនឿលើអ្នកដទៃ ខ្លាចមនុស្សប្រភេទណាមួយ ។
- ប្រព្រឹត្តអំពើផ្លូវភេទដោយប្រើឧបករណ៍ផ្សេងៗ ។
- គូររូប ឬរៀបរាប់អំពីទង្វើផ្លូវភេទបែបអាសអាភាសខ្លាំង ទាំងអាយុរបស់ខ្លួនមិនសក្តិសមនឹងទង្វើនោះ ។

- ចំណេះដឹងផ្នែកផ្លូវភេទដែលមានលក្ខណៈចម្លែកខ្លាំង ស្មុគស្មាញ ឬខុសប្លែកពីធម្មតា ។
- ត្រលប់ទៅរកការដេកនាំដាក់ខោ/ជុះអាចម៍ដាក់ខោ ។
- ផ្លាស់ប្តូរអាកប្បកិរិយាឆាប់រហ័ស ផ្លាស់ប្តូរភ្លាមៗទៅជាលែងចូលរួមសកម្មភាពនានា ។
- មានទំនាក់ទំនងមិនល្អជាមួយកុមារដទៃ និងឲ្យតម្លៃខ្លួនឯងទាប ។
- មិនចេះថែទាំខ្លួនឯង ។
- មានការថប់បារម្ភខ្លាំងជ្រុល ។
- មានអាកប្បកិរិយាដដែលៗដូចជាយោលខ្លួនទៅមក បៀបដៃ ឬបំពានលើខ្លួនឯង ។
- មានការលំបាកក្នុងការកសាងទំនាក់ទំនងជាមួយកុមារដទៃ និងមនុស្សពេញវ័យ ។

ចំពោះកុមារដែលមានអាយុច្រើនៈ

- ប្តូរទៅជាគ្មានចំណាប់អារម្មណ៍ជាមួយមិត្តភក្តិ ឬសកម្មភាពនានា ។
- ខ្លាច និងមានអាការៈងាយភ្ញាក់ផ្អើលដោយសារប៉ះពាល់ ឬនៅពេលមានមនុស្សដើរចូលមកជិតកុមារនោះ ។
- ខិតខំយ៉ាងខ្លាំងក្នុងការជៀសវាងពីមនុស្សណាម្នាក់ដោយគ្មានមូលហេតុច្បាស់លាស់ ។
- គេចវេសពីមនុស្សដែលមានភេទដូចគ្នាទៅនឹងភេទរបស់ជនរំលោភបំពាន ។
- មានចំណាប់អារម្មណ៍ខ្លាំងទៅលើសកម្មភាពផ្លូវភេទ ។
- ប្រឆាំង ឬជំទាស់ទៅនឹងមនុស្សធំ ឬអ្នកមានអំណាច ។
- ត្រូវការអ្នកណាម្នាក់នៅជាមួយគាត់ជានិច្ច ។
- ការប្រាស្រ័យទាក់ទងមានលក្ខណៈកាន់តែអន់ទៅៗ ។
- មានការលំបាកក្នុងការរៀនសូត្រ ឬការសិក្សាមានការធ្លាក់ចុះជាខ្លាំង ។
- គេចសាលា ឬចាកចោលផ្ទះ ។
- ស្លៀកពាក់បែបសិចស៊ី ឬបែបបិទបាំងមិនឲ្យមានអារម្មណ៍ផ្លូវភេទ ។
- ការកើតមានឡើងនូវជម្ងឺផ្នែករាងកាយដែលបណ្តាលមកពីបញ្ហាផ្លូវចិត្ត (ឈឺពោះ ឈឺក្បាល ចង់ក្អួត) ។
- ខ្វះការទុកចិត្តចំពោះអ្នកដទៃ ។
- មិនអាច " លេងសើចសប្បាយ "ជាមួយអ្នកដទៃ ។
- ប៉ុនប៉ងសម្លាប់ខ្លួន ។
- សេពគ្រឿងញៀន/គ្រឿងស្រវឹង ។
- គ្មានអនាម័យផ្ទាល់ខ្លួន ។

- ភាពមានដៃគូច្រើន ។
- មានការសម្តែងចេញនូវសកម្មភាពផ្លូវភេទជាច្រើនផ្សេងៗគ្នា ។
- ការបំផ្លិចបំផ្លាញខ្លួនឯង ដូចជាអារដៃ ជើង ចាក់ ឬសាក់លើខ្លួន ។
- មានការដូ លុយកាក់ ឬអំណោយជាបន្តបន្ទាប់ដោយគ្មានការពន្យល់ច្បាស់លាស់ ។
- បង្ហាញនូវភាពឃោឃៅចំពោះសត្វ ។
- ចូលចិត្តដុតភ្លើង ។

២.**<u>សូចនាករតាមរយៈអ្នកថែរក្សា</u>**

- ឲ្យតម្លៃខ្លួនឯងទាប ។
- មានការទំនាក់ទំនងនៅខាងក្រៅ/សង្គមតិចតួច ។
- ច្រណែននឹងកុមារ ។
- ធ្វើសកម្មភាពការពារកុមារជ្រុល ។
- ប្រព្រឹត្តចំពោះកុមារដែលកំពុងលូតលាស់ហាក់ដូចជាកុមារនោះមានអាយុក្មេងជាងអាយុពិតរបស់ពួកគេ (ឧ: ចង់ឲ្យកុមារដែលមានអាយុច្រើនស្លៀកពាក់ដូចកុមារតូចៗ) ។
- មានលក្ខណៈការពារឯកជនភាពរបស់កុមារជ្រុល ។
- ហាមឃាត់មិនឲ្យកុមារចូលរួមសកម្មភាពនានាជាមួយកុមារដទៃ ។
- យកកុមារទៅពាក់ព័ន្ធជាមួយនឹងទង្វើពេស្យាចារ ។
- បង្ហាញរូបភាពអាសអាភាសឲ្យកុមារមើលឃើញ ។

## ក. ទស្សនៈវិស័យ

ចង់ឃើញសង្គមកម្ពុជាមួយដែលសិទ្ធិអំណាចយុវជនគ្រប់ជំនាន់ ត្រូវបានទទួលស្គាល់ក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសប្រកបដោយចេរភាព ។

## ខ. បេសកកម្ម

យុវជនធ្វើការរួមគ្នាដើម្បីពង្រឹងនិងពង្រីកការចូលរួមរបស់យុវជននៅក្នុងកិច្ចការសង្គម តាមរយៈការកសាងសមត្ថភាព ការអប់រំផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ បរិស្ថាន សុខភាព ព្រមទាំងការតស៊ូមតិឲ្យមានការផ្លាស់ប្តូរស្ថានភាពយុវជនកម្ពុជា ។

## គ.គោលបំណង

ធានាឲ្យមានសម្លេងដ៏រឹងមាំរបស់យុវជន ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងជំរុញឲ្យមានការបង្កើត និងការអនុវត្តគោលនយោបាយយុវជនជាតិមួយប្រកបដោយប្រសិទ្ធិភាព ។

## ឃ.គុណតម្លៃ

- សាមគ្គីភាព
- ប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យ
- អហិង្សា
- តម្លាភាព និងគណនេយ្យភាព
- យែនឌ័រ

សម្ព័ន្ធយុវជនដើម្បីឯកភាពនិងអភិវឌ្ឍន៍

YCUD

Youth Coalition for Unity and Development